**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

PHNOM PENH WATER SUPPLY AUTHORITY

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
លេខ : ១០៣ /ក្រុបភ./ សសវ

# សេចក្តីសម្រេច
# ស្តីពី
# ការតែងតាំងសមាសភាពគណៈកម្មាធិការសវនកម្ម

## ក្រុមប្រឹក្សាភិបាលរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អាណត្តិទី៨

- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៦ ស្តីពីការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០០ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៦ ស្តីពីការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ០៨ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការកែសម្រួលមាត្រា៥ថ្មី នៃអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០០ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៦ ស្តីពីការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ៤១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៧១ អនក្រ.បក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១ ស្តីពីការបំពេញបន្ថែមលើអនុក្រឹត្យលេខ៤១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៣១ អនក្រ.តត ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២៣ ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាលរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អាណត្តិទី៨
- បានឃើញអនុក្រឹត្យលេខ៣៧៨ អនក្រ.តត ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ ស្តីពីការតែងតាំងអគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ និងសមាជិកក្រុមប្រឹក្សាភិបាលរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- បានឃើញប្រកាសលេខ០១១/១៨ គ.ម.ក/ប្រ.ក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីអភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- យោងកំណត់ហេតុលេខ ០៣៣ ក.ប.ក ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣ ស្តីពីលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងនិយោជិតអាណត្តិទី៨ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- យោងកំណត់ហេតុប្រជុំលើកទី១ របស់ក្រុមប្រឹក្សាភិបាលអាណត្តិទី៨ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣

## សម្រេច

**ប្រការ ១** : ត្រូវបានតែងតាំងសមាសភាពគណៈកម្មាធិការសវនកម្ម ដូចខាងក្រោម ៖

| | | |
|---|---|---|
| ១. **លោក ស្រេង សំឌិក** | សមាជិកក្រុមប្រឹក្សាភិបាល<br>អភិបាលឯករាជ្យ | ប្រធាន |
| ២. **ឯកឧត្តម ម៉ី វ៉ាន់** | សមាជិកក្រុមប្រឹក្សាភិបាល<br>តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |

៣. **លោក ណាំ ចន្ទ្រី** សមាជិកក្រុមប្រឹក្សាភិបាល អភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន — សមាជិក

៤. **ឯកឧត្តម នេត មុន្នី** មន្ត្រីត្រួតពិនិត្យរដ្ឋអម រ.ទ.ស.ភ — សមាជិក

៥. **លោក ម៉ា ណូវ៉ាទីន** សមាជិកក្រុមប្រឹក្សាភិបាល តំណាងនិយោជិត រ.ទ.ស.ភ — សមាជិក

**ប្រការ ២** : គណៈកម្មាធិការសវនកម្ម ត្រូវបំពេញតួនាទី និងភារកិច្ចដូចមានចែងក្នុងប្រកាសលេខ០១១/២៨ គ.ម.គ/ប្រ.ក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ របស់គណៈកម្មការមូលបត្រកម្ពុជា ស្តីពីអភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ។

**ប្រការ ៣** : បទបប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៤** : គ្រប់សមាជិកក្រុមប្រឹក្សាភិបាល សាមីខ្លួនដូចមានឈ្មោះក្នុងប្រការ១ និងគ្រប់មន្ត្រីជាន់ខ្ពស់ក្នុងក្របខ័ណ្ឌរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ត្រូវទទួលអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៧កើត ខែ ចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ២០២៣

**ជ. ក្រុមប្រឹក្សាភិបាល**

**ប្រធាន**

**ស៊ឹម ស៊ីថា**

ចម្លងជូន :

- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- និយ័តករមូលបត្រកម្ពុជា
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ